**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានសិក្សាចិន**
នាយកដ្ឋានសេដ្ឋកិច្ចនិងការអភិវឌ្ឍចិន

# និន្នាការសេដ្ឋកិច្ចសង្គម ចិន

## មិថុនា ២០២៥



## បុព្វកថាអ្នករៀបរៀង

ខែឧសភា ឆ្នាំ ២០២៥ ការនាំចេញទំនិញរបស់ចិនមានការកើនឡើង ដែលបានបង្ហាញពីសញ្ញាងើបឡើងវិញនៃសេដ្ឋកិច្ចចិន ការនាំចូលប្រទេសចិន មានការថយចុះបង្ហាញពីការថយចុះ មិនទាន់ងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។ ប្រទេសចិនមានមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ ដែលនឹងជួយរុញកំណើនសេដ្ឋកិច្ចពិភពលោក។

ជាអ្នករៀបរៀងខ្ញុំបាទ ក្នុងពេលបំពេញភារកិច្ច ក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយខ្ញុំបាទបានរៀនសូត្រពី វិធីសាស្ត្រគណនាកំណើន ពី ឯកឧត្តម គឹម ផល្លា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មុនចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំបាទបានរៀនសូត្រពីស្ថិតិអនុវត្តិពី អ្នកជំនាញ (Expert) នៃ ធនាគារពិភពលោក (World Bank) សាស្ត្រាចារ្យ Michele Bruni ក្នុងពេលខ្ញុំបម្រើការក្នុង ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងខ្ញុំបានសិក្សាស្ថិតិវិទ្យា និងសេដ្ឋមាត្រសាស្ត្រ ពីសាស្ត្រាចារ្យ Honda Yuzo និងសាស្ត្រាចារ្យ Ban Kanami នៃសាកលវិទ្យាល័យ Osaka និងសាស្ត្រាចារ្យ Maesono Yoshihiko និង សាស្ត្រាចារ្យ Saeki Chikayoshi នៃសាកលវិទ្យាល័យ Kyushu។

ខ្ញុំបាទសង្ឃឹម កិច្ចការ ស្រាវជ្រាវ និងតាមដានព័ត៌មានសេដ្ឋកិច្ចសង្គម ចិន នេះ នឹងអាចជាអត្ថប្រយោជន៍ ដល់អ្នកសិក្សាស្រាវជ្រាវពីសេដ្ឋកិច្ចសង្គមចិន។ របាយការណ៍នេះ គ្រាន់តែជា Flash Report ដែលមិនស៊ីជម្រៅ សម្រាប់សេដ្ឋកិច្ចជាក់ស្តែង។

ថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥
អ្នករៀបរៀង
ជឹម សុជាតិ (MSc. In Economics)

# ក្រាហ្វិកនៃនិន្នាការសេដ្ឋកិច្ចចិន












# ស្ថានភាពនិន្នាការសេដ្ឋកិច្ចចិន

នៅខែមេសាឆ្នាំ ២០២៥ ប្រទេសចិនបាននាំចេញទំនិញមានតម្លៃ ៣១៦,១ ប៊ីលានដុល្លារ កើនឡើង ០,២% ធៀបនឹងខែមេសាឆ្នាំ ២០២៥ ធៀបរយៈពេលដូចគ្នាឆ្នាំមុនការនាំចេញកើនឡើង ៤,៧% ចំណែកការនាំចូលរបស់ចិនមាន ២១២,៩ ប៊ីលានដុល្លារ ថយចុះ ៣,០% ធៀបនឹងខែមេសាឆ្នាំ ២០២៥ ធៀបរយៈពេលដូចគ្នាឆ្នាំមុនការនាំចូលថយចុះ ៣,៣%។ អតិផរណារបស់ចិនខែឧសភាឆ្នាំ ២០២៥ មាន -0.1% ធៀបនឹងខែដូចគ្នាឆ្នាំមុន មានអត្រាដូចគ្នាក្នុងរយៈពេល៣ខែមុន ។ អត្រាប្តូរប្រាក់ រូបិយបណ្ណ យ៉ន់របស់ចិន 7.16 យ៉ន់/ដុល្លារ ក្នុងខែ ឧសភា ២០២៥ យ៉ន់ ឡើងតម្លៃធៀបដុល្លារ បង្ហាញពីការរឹងមាំ របស់ប្រព័ន្ធហិរញ្ញវត្ថុចិន។

យោងតាម The Nation ប្រទេសថៃខាតបង់ ១៥ លានដុល្លារ/១ថ្ងៃ ពីជម្លោះកម្ពុជាថៃ។ ប្រទេសថៃនាំចូលទំនិញមានតម្លៃ ៥ ពាន់លានដុល្លារក្នុងឆ្នាំ ចូលប្រទេសកម្ពុជា។ ប្រទេសថៃពឹងផ្អែកខ្លាំងលើកម្លាំងពលកម្មកម្ពុជា ហើយនាំចេញទំនិញមកកម្ពុជាមាន ប្រេងឥន្ធនៈ គ្រឿងចក្រ ភេសជ្ជៈ ទំនិញប្រើប្រាស់ប្រចាំថ្ងៃរបស់កម្ពុជា។

ដំណោះស្រាយសម្រាប់ជម្លោះ កម្ពុជាថៃ គឺបណ្តាលមកពី កត្តាប្រវត្តិសាស្ត្រ ដែលខ្វះការគោរពរបស់ភាគី ពាក់ព័ន្ធ ជាពិសេសប្រទេសថៃ ដែលដឹងច្បាស់ពីអរិយធម៌ និងវប្បធម៌របស់ប្រទេសកម្ពុជា តាំងតែពីអតីតកាល។ ដំណោះស្រាយមានតែ គោលនយោបាយសន្តិភាព និងយុទ្ធសាស្ត្រ ផលប្រយោជន៍ទៅវិញទៅមក ដោយការគោរព ដែនដីគ្នាទៅវិញទៅមក។

**<u>អនុសាសន៍របស់ លោកប្រធានាធិបតីចិន ៖</u>**

សៀវភៅទំនើបកម្មប្រទេសចិន Discourses on Chinese modernization ដែលបានបាឋកថាដោយ លោកប្រធានាធិបតីចិន ស៊ី ជីងភីន ត្រូវបានផ្សព្វផ្សាយនៅប្រទេសជប៉ុន “Chinese modernization is the crystallization of Eastern wisdom that promotes the progress of human civilization, a "monument of the times" forged by the Communist Party of China (CPC) in uniting and leading the people through a century-long journey, a path of human justice that takes root in the land of China and shines with the light of truth, as well as the epitome of Xi's thoughts on governing the country.” ។

លោកប្រធានាធិបតីចិន ស៊ី ជីងភីន នឹងអញ្ជើញទៅកិច្ចប្រជុំចិន-អាស៊ីកណ្តាល China-Central Asia Summit នៅ Astana រដ្ឋធានី របស់ប្រទេស Kazakhstan ១៦ ដល់ ១៨ មិថុនា “For centuries, China and Central Asian nations have shared close bonds through mutual learning and exchanges underpinned by deep historical ties, solid public support and strong practical needs.” ។

លោកប្រធានាធិបតីចិន ស៊ី ជីងភីន នៅក្នុងការពិភក្សាសន្ទនា ទូរសព្ទជាមួយប្រធានាធិបតី សហរដ្ឋអាមេរិក Donald Trump បានមានប្រសាសន៍ថា “Dialogue and cooperation are the only correct choice for China and the United States. The two sides need to make good use of the economic and trade consultation mechanism already in place, and seek win-win results in the spirit of equality and respect for each other's concerns, he said, adding that the Chinese side is sincere about this, and at the same time has its principles. The U.S. side should acknowledge the progress already made, and remove the negative measures taken against China” ។

**សេដ្ឋកិច្ចនយោបាយ៖** ការវាយប្រហាររបស់សហរដ្ឋអាមេរិកលើទីតាំងនុយក្លេអ៊ែររបស់អ៊ីរ៉ង់បង្កឱ្យមានការបារម្ភនៃជម្លោះកាន់តែធំ ក្រោយពីសហរដ្ឋអាមេរិក ប្រធានាធិបតី ត្រាំ និយាយពីវាយប្រហារលើប្រទេសអ៊ីរ៉ង់ (three nuclear sites មាន Fordow, Natanz និង Esfahan)។

នាយករដ្ឋមន្ត្រីថៃ ផេថងថាន ស៊ីណាវ៉ាត់ បាននិយាយថា ""The military has confirmed readiness for any scenario. But any clash will cause damage, so we will pursue peaceful means. The government and military are working together, supporting each other"។ កងទ័ពថៃបាននិយាយថា "Operations of units at the border have been conducted carefully, calmly and based on an understanding of the situation to prevent losses on all sides, but at the same time, are ready to defend the country's sovereignty to the fullest extent if the situation is called for."។

កម្ពុជា និងថៃ បានបើកិច្ចប្រជុំនៅ ភ្នំពេញ ដើម្បីបន្ថយភាពតានតឹង បណ្តាលមកពីភាគីថៃ ពង្រាយកងទ័ពនៅតំបន់ប្រាសាទតាមាន់ទឹកដីប្រទេសកម្ពុជា។ នាយករដ្ឋមន្ត្រីថៃ ផេថងថាន ស៊ីណាវ៉ាត់ បាននិយាយក្នុង Facebook ថា "The Thai government has no policy to repatriate alien workers from any country from the kingdom, but if any country takes measures to call back workers with jobs having been created for them, they have the right and freedom to decide under the responsibility of their country,"។

**សេដ្ឋកិច្ចសង្គម៖** រាជរដ្ឋាភិបាលកម្ពុជា បានដាក់ពាក្យបណ្តឹងការដាក់កងទ័ព របស់ប្រទេសថៃនៅជុំវិញប្រាសាទតាមន់ទៅកាន់ តុលាការអន្តរជាតិ International Court of Justice។ នេះជាដំណោះស្រាយសមស្របតាមស្ថានការណ៍។

អ៊ីស្រាអែលនិយាយថា ខ្លួនបានកំណត់អត្តសញ្ញាណកាំជ្រួចបន្ថែមទៀតដែលបាញ់ចេញពីប្រទេសអ៊ីរ៉ង់ ហើយបច្ចុប្បន្នកំពុងធ្វើការដើម្បីស្ទាក់ចាប់កាំជ្រួចរបស់អ៊ីរ៉ង់។ អ៊ីស្រាអែលបានបាញ់កាំជ្រួច ទៅអ៊ីរ៉ង់កាលពីថ្ងៃសុក្រ សប្តាហ៍មុន។

អាជ្ញាធរហិរញ្ញវត្ថុចិន ពិចារណាអនុញ្ញាតឱ្យអាជ្ញាធរដូរទ្រព្យសម្បត្តិឌីជីថល Crypto ជាលុយពិតតាមរយៈការផ្លាស់ប្តូរដែលមានអាជ្ញាប័ណ្ណនៅក្នុងទីក្រុងហុងកុងតាមរបៀបមួយដែលកែប្រែបទបញ្ញត្តិហាមឃាត់ ទ្រព្យសម្បត្តិឌីជីថល Crypto។

សភារបស់ប្រទេសអ៊ីរ៉ង់បានបោះឆ្នោតបិទច្រកជឹកជញ្ជូន Hormuz ដ៏សំខាន់នៅក្នុងប្រឆាំងនឹងការវាយប្រហាររបស់លោក Donald Trump មកលើប្រទេសអ៊ីរ៉ង់ ដោយជំរុញឱ្យមានការព្រួយបារម្ភអំពីការកើនឡើងយ៉ាងខ្លាំងនៃតម្លៃប្រេងដែលអាចបណ្តាលឱ្យមានវិបត្តិសេដ្ឋកិច្ចពិភពលោក។ ប្រេងឆៅ Brent មួយធុងត្រូវបានលក់ក្នុងតម្លៃប្រហែល 77 ដុល្លារកាលពីថ្ងៃសុក្រ ដោយបានកើនឡើងជាង 10% ចាប់តាំងពីពាក់កណ្តាលខែមិថុនា នៅពេលដែលការវាយប្រហាររបស់អ៊ីស្រាអែលលើទីតាំងនុយក្លេអ៊ែរអ៊ីរ៉ង់។

បញ្ហាជម្លោះប្រទេសកម្ពុជាថៃ ជាបញ្ហាមានលក្ខណៈប្រវត្តិសាស្ត្រ និងបញ្ហានយោបាយក្រៅប្រទេសរបស់ថៃ ដែលថៃមានបញ្ហាផ្ទៃក្នុងរបស់ប្រទេសខ្លួន ហើយយកបញ្ហាស្ថានការណ៍ព្រំដែន ដើម្បីបំភ្លេចស្ថានការណ៍ក្នុងប្រទេសថៃ។ ប្រទេសកម្ពុជា ប្រកាន់គោលការណ៍សន្តិភាព និងស្វ័យការពារ ដើម្បីចៀសវាងសង្គ្រាម និងការខាតបង់ផ្នែកវិស័យសេដ្ឋកិច្ច និងទំនាក់ទំនងអន្តរជាតិ។

បញ្ហាទំនាស់តាមព្រំដែនដូចជា រុស្ស៊ីអ៊ុយក្រែន ឥណ្ឌាប៉ាគីស្ថាន អ៊ីស្រាអែលអីរ៉ង់ ជាបញ្ហាតានតឹងសម្រាប់ពិភពលោកសព្វថ្ងៃ ។ មហាអំណាចចិន បានប្រកាន់គោលការណ៍ និងគោលជំហរ សន្តិភាព និងសហប្រតិបត្តិការសាកល ដើម្បសន្តិភាពពិភពលោក និងផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ប្រទេសនីមួយៗ។ ការប្រឈមមុខដាក់គ្នានៃកងទ័ពកម្ពុជា និងថៃ មានភាពធូរស្រាលបន្ទាប់ពីជំនួបកម្ពុជាថៃ នៅភ្នំពេញ ដោយថ្នាក់ដឹកនាំកម្ពុជាថៃចៀសវាងការប្រយុទ្ធទ្រង់ទ្រាយធំ។

ប្រធានាធិបតីអាមេរិក លោក Trump បាននិយាយថា សហរដ្ឋអាមេរិក មិនមានជាប់ពាក់ព័ន្ធ ទៅនឹងការវាយប្រហាររបស់អ៊ីស្រាអែល ប៉ុន្តែក្រោយមកបានទទួលស្គាល់ថា ការចូលរួមរបស់សហរដ្ឋអាមេរិកនៅក្នុងជម្លោះគឺជាលទ្ធភាព មួយ។

បញ្ហាទំនាស់តាមព្រំដែនដូចជា រុស្ស៊ីអ៊ុយក្រែន ឥណ្ឌាប៉ាគីស្ថាន អ៊ីស្រាអែលអីរ៉ង់ ជាបញ្ហាតានតឹងសម្រាប់ពិភពលោកសព្វថ្ងៃ ។ មហាអំណាចចិន បានប្រកាន់គោលការណ៍ និងគោលជំហរ សន្តិភាព និងសហប្រតិបត្តិការសាកល ដើម្បសន្តិភាពពិភពលោក និងផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ប្រទេសនីមួយៗ។ ការប្រឈមមុខដាក់គ្នានៃកងទ័ពកម្ពុជា និងថៃ មានភាពធូរស្រាលបន្ទាប់ពីជំនួបកម្ពុជាថៃ នៅភ្នំពេញ ដោយថ្នាក់ដឹកនាំកម្ពុជាថៃចៀសវាងការប្រយុទ្ធទ្រង់ទ្រាយធំ។

ប្រធានាធិបតីអាមេរិក លោក Trump បាននិយាយថា សហរដ្ឋអាមេរិក មិនមានជាប់ពាក់ព័ន្ធ ទៅនឹងការវាយប្រហាររបស់អ៊ីស្រាអែល ប៉ុន្តែក្រោយមកបានទទួលស្គាល់ថា ការចូលរួមរបស់សហរដ្ឋអាមេរិកនៅក្នុងជម្លោះគឺជាលទ្ធភាព មួយ។

**ប្រភពទិន្នន័យ &ព័ត៌មាន៖**

- Xinhua
- China National Bureau of Statistics
- Ministry of Commerce People Republic of China
- Statista
- China Foreign Exchange Trade System
- Tradingeconomics
- CNN
- The Bangkok Post
- Caixin
- Reuters
- atlanta
- ychart
- globaltime
- Nikkei
- U.S. Bureau of Economic Analysis